ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ

លេខ៖ បព ១៦២/២០២៦ កបទ.សអ

សេចក្តីប្រកាសព័ត៌មាន

លទ្ធផលនៃជំនួបពិភាក្សាទ្វេភាគីរវាង ឯកឧត្តម ប្រាក់ សុខុន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ជាមួយរដ្ឋមន្ត្រីការបរទេស និងប្រធានគណៈប្រតិភូ ដែលអញ្ជើញចូលរួមកិច្ចប្រជុំកំពូលហ្វ្រង់កូហ្វូនីលើកទី២០ នៅរាជធានីភ្នំពេញ ពីថ្ងៃទី១៤ ដល់១៥ ខែវិច្ឆិកា ឆ្នាំ២០២៦

ពីថ្ងៃទី១៤ ដល់១៥ ខែវិច្ឆិកា ឆ្នាំ ២០២៦ ក្នុងឱកាសនៃសន្និសីទថ្នាក់រដ្ឋមន្ត្រីហ្វ្រង់កូហ្វូនី លើកទី៤៨ និងកិច្ចប្រជុំកំពូលហ្វ្រង់កូហ្វូនី លើកទី២០ ដែលប្រព្រឹត្តទៅនៅរាជធានីភ្នំពេញ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន** រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នៃព្រះរាជាណាចក្រកម្ពុជា បានជួបពិភាក្សាការងារទ្វេភាគីជាមួយរដ្ឋមន្ត្រីការបរទេស និងប្រធានគណៈប្រតិភូមួយចំនួន ដែលអញ្ជើញចូលរួមសន្និសីទថ្នាក់រដ្ឋមន្ត្រី និងកិច្ចប្រជុំកំពូលហ្វ្រង់កូហ្វូនីខាងលើ។

នៅក្នុងជំនួបទ្វេភាគីជាមួយ **ឯកឧត្តម** CHANG Jae Bok តំណាងរដ្ឋាភិបាលសាធារណរដ្ឋកូរ៉េ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានបានថ្លែងអំណរគុណរដ្ឋាភិបាលសាធារណរដ្ឋកូរ៉េ ចំពោះការបន្តចូលរួមយ៉ាងសកម្មក្នុងអង្គការអន្តរជាតិហ្វ្រង់កូហ្វូនី(OIF) និងកិច្ចប្រជុំកំពូលហ្វ្រង់កូហ្វូនីលើកទី២០ ក្នុងនាមជាសមាជិកសង្កេតការណ៍របស់ OIF។ ភាគីសាធារណរដ្ឋកូរ៉េ បានអបអរសាទរកម្ពុជាក្នុងការធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំកំពូលនេះ ដោយជោគជ័យ។ ភាគីទាំងពីរបានសម្តែងនូវការពេញចិត្តចំពោះសន្ទុះវិជ្ជមាននៃទំនាក់ទំនងទ្វេភាគីនិងទន្ទឹងរង់ចាំប្រារព្ធខួបលើកទី៣០ នៃការភ្ជាប់ទំនាក់ទំនងការទូតឡើងវិញរវាងកម្ពុជា និងសាធារណរដ្ឋកូរ៉េ នៅឆ្នាំ២០២៧។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានគូសបញ្ជាក់អំពីសារៈសំខាន់នៃការបន្តពង្រឹងបន្ថែមទៀតនូវចំណងមិត្តភាពដ៏យូរអង្វែង និងភាពជាដៃគូយុទ្ធសាស្ត្ររវាងប្រទេសទាំងពីរ។ ពាក់ព័ន្ធនឹងកិច្ចសហប្រតិបត្តិការប្រយុទ្ធប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែន ជាពិសេសការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានបញ្ជាក់ជាថ្មីនូវការប្តេជ្ញាចិត្តយ៉ាងមុតមាំរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការប្រយុទ្ធប្រឆាំង និងលុបបំបាត់ការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា។ ភាគីសាធារណរដ្ឋកូរ៉េ បានកោតសរសើរចំពោះកិច្ចខិតខំប្រឹងប្រែង និងកិច្ចសហប្រតិបត្តិការយ៉ាងសកម្មរបស់កម្ពុជា ក្នុងការប្រយុទ្ធប្រឆាំងការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា និងការការពារសុវត្ថិភាពពលរដ្ឋកូរ៉េ។

អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីម៉ែល: mfaic@mfaic.gov.kh

ក្នុងជំនួបជាមួយ **ឯកឧត្តម** Lejeune Mbella Mbella រដ្ឋមន្ត្រីការបរទេស នៃសាធារណរដ្ឋកាមេរូន ភាគីទាំងពីរបានឯកភាពគ្នាបញ្ចប់នីតិវិធីសម្រាប់បង្កើតទំនាក់ទំនងការទូតរវាងកម្ពុជា និងកាមេរូន ក្នុងពេលឆាប់ៗខាងមុខនេះ ហើយបន្ទាប់មកនឹងរៀបចំឱ្យមានការពិគ្រោះយោបល់ផ្ទៃកនយោបាយរវាងក្រសួងការបរទេសនៃប្រទេសទាំងពីរ ដើម្បីពង្រឹងទំនាក់ទំនងទ្វេភាគីបន្ថែមទៀត។ ភាគីទាំងពីរក៏បានផ្លាស់ប្តូរទស្សនៈស្តីពីការពង្រឹងកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច ជាពិសេសតាមរយៈការផ្លាស់ប្តូរដំណើរទស្សនកិច្ច និងបេសកកម្មសេដ្ឋកិច្ច ដោយផ្តោតសំខាន់លើវិស័យកសិកម្ម។ លើសពីនេះ ភាគីទាំងពីរក៏បានផ្លាស់ប្តូរទស្សនៈអំពីកិច្ចសហប្រតិបត្តិការលើកិច្ចការកុងស៊ុល ព្រមទាំងឱកាសសម្រាប់កិច្ចសហការក្នុងវិស័យសមុទ្រ និងកំពង់ផែ ផងដែរ។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានថ្លែងអំណរគុណប្រទេសកាមេរូន ដែលបានចូលរួមក្នុងកិច្ចប្រជុំកំពូលហ្វ្រង់កូហ្វូនីលើកទី២០។

នៅក្នុងជំនួបរវាង **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** និង**ឯកឧត្តម** Barry Faure រដ្ឋមន្ត្រីក្រសួងការបរទេសនៃសាធារណរដ្ឋសីស្ហែល ភាគីទាំងពីរ បានពិភាក្សាអំពីការពង្រឹងកិច្ចសហប្រតិបត្តិការទ្វេភាគីលើ វិស័យពាណិជ្ជកម្ម វិនិយោគ ទេសចរណ៍ វប្បធម៌ និងការផ្លាស់ប្តូររវាងប្រជាជននិងប្រជាជន។ ភាគីទាំងពីរបានសង្កត់ធ្ងន់លើសារៈសំខាន់នៃការបង្កើនការផ្លាស់ប្តូរទស្សនកិច្ចកម្រិតខ្ពស់ និងកិច្ចសហប្រតិបត្តិការរវាងស្ថាប័ននានា។ ភាគីទាំងពីរបានស្វាគមន៍យ៉ាងកក់ក្តៅចំពោះខួបលើកទី៣០ នៃការបង្កើតទំនាក់ទំនងការទូតរវាងប្រទេសទាំងពីរនៅឆ្នាំនេះ ហើយបានសម្តែងការពេញចិត្តចំពោះកិច្ចព្រមព្រៀងដែលមានស្រាប់ សំដៅពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរ។ ភាគីទាំងពីរក៏បានពិភាក្សាអំពីការសម្រួលដល់ការធ្វើដំណើរ ការជំរុញវិស័យទេសចរណ៍ និងការផ្លាស់ប្តូររវាងប្រជាជននិងប្រជាជន រួមទាំង ការពិចារណាលើលទ្ធភាពរៀបចំផ្តល់ទិដ្ឋាការសម្រាប់ការស្នាក់នៅរយៈពេលយូរជាងមុនផងដែរ។ **ឯកឧត្តម** Barry Faure បានបង្ហាញពីចំណាប់អារម្មណ៍របស់ប្រទេសសីស្ហែល ក្នុងការរៀនសូត្រពីបទពិសោធន៍ និងជំនាញរបស់កម្ពុជា លើការងារអភិរក្ស និងការលើកកម្ពស់បេតិកភណ្ឌវប្បធម៌។

នៅក្នុងជំនួបជាមួយ **លោកជំទាវ** Fatimé Aldjineh Garfa រដ្ឋមន្ត្រីប្រតិភូអមរដ្ឋមន្ត្រីក្រសួងការបរទេសសមាហរណកម្មអាហ្វ្រិក និងជនជាតិឆាដដែលរស់នៅបរទេស នៃសាធារណរដ្ឋឆាដ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន** បានផ្តោតការពិភាក្សាលើការស្វែងរកឱកាសសម្រាប់កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច។ ភាគីទាំងពីរបានបញ្ជាក់ជាថ្មីនូវការត្រៀមខ្លួនជាស្រេច ក្នុងការធ្វើឱ្យកាន់តែស៊ីជម្រៅនូវទំនាក់ទំនងទ្វេភាគី និងការសម្របសម្រួលយ៉ាងជិតស្និទ្ធលើបញ្ហាតំបន់ និងអន្តរជាតិ នៅក្នុងក្របខ័ណ្ឌនៃអង្គការសហប្រជាជាតិ (UN) និងអង្គការអន្តរជាតិហ្វ្រង់កូហ្វូនី (OIF)។ ភាគីទាំងពីរបានប្តេជ្ញារក្សាការសន្ទនាជាប្រចាំ មិនត្រឹមតែដើម្បីលើកកម្ពស់ទំនាក់ទំនងទ្វេភាគីឱ្យកាន់តែជិតស្និទ្ធប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងដើម្បីរួមចំណែកដល់ពហុភាគីនិយមប្រកបដោយប្រសិទ្ធភាព ក្នុងការជំរុញសន្តិភាព វិបុលភាពរួម និងការអភិវឌ្ឍប្រកបដោយចីរភាព ទាំងនៅក្នុង និងក្រៅសហគមន៍ហ្វ្រង់កូហ្វូនី។

នៅថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២៦ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានជួបពិភាក្សាជាមួយ **លោកជំទាវ** Anita Anand រដ្ឋមន្ត្រីការបរទេសកាណាដា។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានគូសបញ្ជាក់អំពីសារៈសំខាន់នៃការដែលកាណាដាបានដំឡើងកម្រិតតំណាងការទូតរបស់ខ្លួននៅកម្ពុជាទៅជាស្ថានឯកអគ្គរដ្ឋទូតពេញលេញ បានបង្កើនការផ្លាស់ប្តូរទស្សនកិច្ចកម្រិតខ្ពស់ និងកំណើននៃពាណិជ្ជកម្ម និងការវិនិយោគ ព្រមទាំងបានបញ្ជាក់ជាថ្មីនូវការប្តេជ្ញាចិត្តរបស់កម្ពុជាក្នុងការបើកស្ថានឯកអគ្គរាជទូតកម្ពុជានៅកាណាដា ក្នុងពេលឆាប់ៗខាងមុខនេះ។ ភាគីទាំងពីរបានសម្តែងការពេញចិត្តចំពោះយន្តការពិគ្រោះយោបល់ទ្វេភាគី រវាងក្រសួងការបរទេសទាំងពីរ ដែលប្រព្រឹត្តទៅជាប្រចាំប្រកបដោយផ្លែផ្កា ការពង្រីកវត្តមានរបស់វិស័យឯកជនកាណាដានៅកម្ពុជា និងការផ្លាស់ប្តូរទស្សនកិច្ចផ្លូវការកម្រិតខ្ពស់។ ភាគីទាំងពីរបានវាយតម្លៃខ្ពស់ចំពោះដំណើរទស្សនកិច្ចផ្លូវការរបស់ **ឯកឧត្តម** Mark Carney នាយករដ្ឋមន្ត្រីកាណាដា មកកាន់ព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃទី១៥ ដល់ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ ២០២៦។ ដំណើរទស្សនកិច្ចនេះគឺជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រដ៏សំខាន់មួយដែលបានពង្រឹងមូលដ្ឋានគ្រឹះនៃកិច្ចសហប្រតិបត្តិការទ្វេភាគីក្នុងវិស័យនយោបាយ-សន្តិសុខ សេដ្ឋកិច្ច និងសង្គម-វប្បធម៌។ ភាគីទាំងពីររំពឹងថានឹងមានការចុះហត្ថលេខាលើកិច្ចព្រមព្រៀងសហប្រតិបត្តិការមួយចំនួន រួមទាំងកិច្ចព្រមព្រៀងស្តីពីការពង្រឹងទំនាក់ទំនងសេដ្ឋកិច្ច និងកិច្ចសហប្រតិបត្តិការក្នុងការប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្មតាមប្រព័ន្ធអ៊ីនធឺណិត ព្រមទាំងការធ្វើការរួមគ្នា ដើម្បីលើកកម្ពស់សិទ្ធិមនុស្ស និងប្រជាធិបតេយ្យ។ លើសពីនេះ ភាគីទាំងពីរ បានពិភាក្សាអំពីឱកាសសម្រាប់កិច្ចសហប្រតិបត្តិការតាមខ្សែច្រវាក់តម្លៃក្នុងវិស័យនានា ជាពិសេសវិស័យកសិកម្ម អវកាស ឧស្សាហកម្មកម្រិតខ្ពស់ និងបច្ចេកវិទ្យា ដើម្បីផលប្រយោជន៍ទៅវិញទៅមករវាងប្រទេសទាំងពីរ។ រដ្ឋមន្ត្រីទាំងពីរ ក៏បានផ្លាស់ប្តូរទស្សនៈស្តីពីការកសាងសហគមន៍និយាយភាសាបារាំង ឱ្យកាន់តែរស់រវើក និងប្រកបដោយសន្តិភាព ក្នុងការដែលកាណាដានឹងកាន់តួនាទីជាប្រធានកិច្ចប្រជុំកំពូលហ្វ្រង់កូហ្វូនីក្នុងឆ្នាំ២០២៨។ ភាគីទាំងពីរក៏បានពិភាក្សាអំពីបញ្ហាតំបន់ និងអន្តរជាតិ ព្រមទាំងកិច្ចសហប្រតិបត្តិការលើបញ្ហាទាំងនោះផងដែរ។

នៅក្នុងជំនួបជាមួយ **ឯកឧត្តម** Xavier BETTEL ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងពាណិជ្ជកម្មក្រៅប្រទេស ព្រមទាំងជារដ្ឋមន្ត្រីក្រសួងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងកិច្ចការមនុស្សធម៌នៃប្រទេសលុចសំបួ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន** បានសម្តែងការពេញចិត្តចំពោះវឌ្ឍនភាពជាលំដាប់នៃទំនាក់ទំនងទ្វេភាគី។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានរំលឹកឡើងវិញអំពីដំណើរទស្សនកិច្ចរបស់ព្រះអង្គម្ចាស់ Guillaume Jean Joseph Marie (Grand Duke) ដែលនៅពេលនោះទ្រង់ជារដ្ឋទាយាទនៃប្រទេសលុចសំបួ កាលពីខែមីនា ឆ្នាំ២០២៤ ដែលបានរួមចំណែកពង្រឹងទំនាក់ទំនងរវាងកម្ពុជា និងលុចសំបួ។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន** បានថ្លែងអំណរគុណចំពោះប្រទេសលុចសំបួ ដែលបានគាំទ្រដល់ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចរបស់កម្ពុជា ជាពិសេសលើវិស័យសុខាភិបាល អប់រំ បណ្តុះបណ្តាលវិជ្ជាជីវៈ អភិវឌ្ឍន៍ជនបទ និងការបោសសម្អាតមីន។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** ក៏បានកោតសរសើរចំពោះការគាំទ្រ និងការចូលរួមយ៉ាងសកម្មរបស់ប្រទេសលុចសំបួ នៅក្នុងកិច្ចប្រជុំកំពូលហ្វ្រង់កូហ្វូនី លើកទី១០ ផងដែរ។ ក្នុងឱកាសនៃជំនួបទ្វេភាគីនោះ កម្ពុជា និងលុចសំបួ បានចុះហត្ថលេខាលើឯកសារកិច្ចសហប្រតិបត្តិការចំនួន ៣

រួមមាន (១) ឯកសារស្តីពីកម្មវិធីណែនាំសម្រាប់កិច្ចសហប្រតិបត្តិការរវាងរាជរដ្ឋាភិបាលកម្ពុជា និងរាជរដ្ឋាភិបាលលុចសំបួ (២) ពិធីសារទ្វេភាគីរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរាជរដ្ឋាភិបាលលុចសំបួ ស្តីពីគម្រោង«គាំទ្រការផ្តល់សេវាដល់សហគមន៍ ចំណេះដឹង សុខភាព និងលទ្ធភាពទទួលបានសេវា និង (៣) ឯកសារផ្តល់អាណត្តិរៀបចំគម្រោងកម្មវិធីអភិវឌ្ឍន៍ជនបទនៅភាគឦសានកម្ពុជា។ ភាគីទាំងពីរទន្ទឹងរង់ចាំការប្រារព្ធខួបលើកទី២៥ នៃការបង្កើតទំនាក់ទំនងការទូតនៅឆ្នាំ ២០២៧ ដោយនឹងមានសកម្មភាពរំលឹកខួបនានា ក្នុងគោលបំណងពង្រឹងបន្ថែមទៀតនូវមិត្តភាពដ៏យូរអង្វែង និងកិច្ចសហប្រតិបត្តិការដែលផ្តល់ផលប្រយោជន៍ទៅវិញទៅមក ដូចជាការផ្លាស់ប្តូរដំណើរទស្សនកិច្ចកម្រិតខ្ពស់ និងការពង្រឹងទំនាក់ទំនងរវាងសភាពាណិជ្ជកម្ម នៃប្រទេសទាំងពីរ។

ថ្ងៃចន្ទ ៧កើត ខែកត្តិក ឆ្នាំមមី អដ្ឋស័ក ព.ស. ២៥៧០
រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២៦